# មេរៀនទី ១២៤៖ ហ្វូងមនុស្សស្វាគមន៍ព្រះយេស៊ូវយាងមកយេរូសាឡិម

## ទំនុកដំកើង ១១៨៖១៩-២៩ ម៉ាថាយ ២១៖១-១១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ **https://youtu.be/4VKSBqR8IP0**

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** **https://youtu.be/MudiC073UKA**

**គោលបំណង៖** ជាការល្អក្នុងការសសើរដំកើងព្រះយេស៊ូវ។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១១៨៖២៦** *"សូមឲ្យព្រះអង្គ ដែលយាងមកដោយនូវព្រះនាមព្រះយេហូវ៉ា បានប្រកបដោយព្រះពរ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ហូសាណានៅស្ថានខ្ពស់បំផុត https://youtu.be/QWQ47zCVaCw

២. ស្តេចលើស្តេច https://youtu.be/CPBqHYVwm3M

៣.ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «ស្តេច ម្ចាស់ក្សត្រី អ្នកបំរើ »**



១. ឲ្យកុមារចាប់ដៃគូពីរៗនាក់ (ប្រុសគូជាមួយប្រុស ស្រីគូជាមួយស្រី )

២. នៅពេលដែលគ្រូ ស្រែកថា "ស្តេច" ដៃគូត្រូវសម្រេចចិត្តឲ្យបានលឿន ថាអ្នកណាត្រូវដើរតួជាស្តេច អ្នកណាត្រូវដើរតួជាអ្នកបំរើ។ អ្នកបំរើត្រូវលុតជង្គង់ចុះ ស្តេចត្រូវអង្គុយនៅលើខ្នងរបស់អ្នកបំរើនោះ។

៣. នៅពេលដែលឮពាក្យថា "ម្ចាស់ក្សត្រី" អ្នកបំរើត្រូវលុតជង្គង់ចុះ ម្ចាស់ក្សត្រីត្រូវដាក់ជង្គង់លើខ្នងរបស់ អ្នកបំរើនោះ។

៤. នៅពេលដែលឮពាក្យថា "អ្នកបំរើ" ពួកគេត្រូវអៀវគ្នា នរណាជាអ្នកអៀវក៏បាន។

៥. ក្រុមដែលមិនធ្វើតាមការណែនាំនឹងចាញ់ល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះ សូមពន្យល់កុមារថា ថ្ងៃនេះយើងនឹងរៀនពីស្តេច គឺព្រះយេស៊ូវគ្រីស្ទ និងការស្វាគមន៍ទ្រង់។

## ៤. ការណែនាំមេរៀន

ប្រសិនបើព្រះយេស៊ូវយាងមកទីក្រុងរបស់អ្នក តើអ្នកនឹងរៀបចំយ៉ាងណាដើម្បីទទួលព្រះអង្គ? តើអ្នកនឹងទះដៃនៅពេលព្រះអង្គយាងចូលទៅក្នុងទីក្រុងដែរឬទេ? តើអ្នកនឹងច្រៀងចម្រៀងដែរឬទេ? តើអ្នកនឹងទទួលបានការស្វាគមន៍ពីមនុស្សជាច្រើន ហើយស្រែកហៅព្រះនាមព្រះយេស៊ូវដែរឬទេ? ព្រះគម្ពីរប្រាប់យើងថា ថ្ងៃមួយព្រះយេស៊ូវបានយាងមកក្នុងក្រុងដោយជិះសត្វលា។ ចូរយើងរកមើលថាតើមនុស្សបានធ្វើអ្វីខ្លះពេលឃើញព្រះអង្គយាងមក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវយាងចូលក្រុងយេរូសាឡិមដោយជិះសត្វលាជាផ្នែកដ៏សំខាន់នៃព័ន្ធកិច្ចរបស់ព្រះយេស៊ូវនៅលើផែនដី។ ព្រះគម្ពីរប្រាប់យើងថា ប្រជាជនរំភើបចិត្តយ៉ាងខ្លាំងនៅថ្ងៃដែលព្រះយេស៊ូវជិះសត្វលាចូលក្រុង។ នេះប្រៀបដូចជាទាហ៊ានម្នាក់ ទួលបានជ័យជម្នះធ្វើដំណើរចូលមកក្នុងទីក្រុងដោយមានមនុស្សសរសើរ និង គោរពគាត់។ មនុស្សម្នាថែមទាំងដាក់អាវរបស់ពួកគេក្រាលនៅលើផ្លូវ ខណៈអ្នកខ្លះទៀតក្រាលធាងចាកនៅលើផ្លូវ។

នៅក្នុងគម្ពីរសញ្ញាចាស់ សាការី ៩៖៩ បានទាយថាស្តេចនឹងចូលទៅក្នុងទីក្រុងដោយជិះលើសត្វលា។ មនុស្សសរសើរតម្កើងថា៖ «ហូសាណាថ្វាយដល់ព្រះរាជបុត្រារបស់ដាវីឌ!»។ «មានពរហើយអ្នកណាដែលមកក្នុងព្រះនាមនៃព្រះយេហូវ៉ា!»។ «ហូសាណានៅស្ថានសួគ៌ខ្ពស់បំផុត! នេះជាការសរសើរពី **ទំនុកដំកើង ១១៨:២៥-២៦**។ នៅទីនោះយើងឃើញពាក្យ "ហូសាណា" ត្រូវបានបកប្រែថា "ព្រះអម្ចាស់សង្គ្រោះយើង!" ដូច្នេះ យើងអាចឃើញថា មនុស្សកំពុងទទួលយក និងសរសើរព្រះយេស៊ូវថា ជាព្រះអង្គសង្គ្រោះ—ព្រះមេស្ស៊ី។ ហើយព្រះយេស៊ូវមិនបានបញ្ឈប់មនុស្សទាំង អស់នោះ ពីការសរសើរទ្រង់ជាព្រះមេស្ស៊ីឡើយ ពីព្រោះទ្រង់ជាព្រះរាជបុត្រានៃព្រះ ដែលបានយាងមក សង្គ្រោះយើង ។ តាមពិត ៥ ថ្ងៃក្រោយមក ព្រះយេស៊ូវត្រូវបានឆ្កាងនៅលើឈើឆ្កាងសម្រាប់អំពើបាបរបស់ យើងទាំងអស់គ្នា។

ព្រះយេស៊ូវសមនឹងទទួលបាននូវការសរសើរ។ យើងត្រូវសរសើរព្រះយេស៊ូវ ពេលយើងនៅម្នាក់ឯង ឬពេលយើងនៅជាមួយអ្នកដទៃ។ ការច្រៀងសរសើរដំកើងព្រះយេស៊ូវជារឿងល្អដែលត្រូវធ្វើ។ ពេលយើងសរសើរព្រះយេស៊ូវ យើងប្រាប់ទ្រង់ថាយើងស្រឡាញ់ព្រះអង្គប៉ុណ្ណា ហើយយើងប្រាប់ព្រះអង្គថា យើងទទួលស្គាល់ថាទ្រង់ជាព្រះដ៏ល្អយ៉ាងណា។ យើងមិនចាំបាច់ចាំទាល់តែឃើញព្រះយេស៊ូវដើម្បីសរសើរទ្រង់ឡើយ។ ព្រះអង្គអាចស្តាប់អ្វីទាំងអស់ដែលយើងនិយាយ ទ្រង់ថែមទាំងដឹងពីអ្វីដែលយើង

កំពុងគិត។ សូមថ្វាយការសរសើរដល់ព្រះយេស៊ូវឥឡូវនេះ។

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវយាងចូលទីក្រុងណា? *(ក្រុងយេរូសាឡិម)*

២. តើព្រះអង្គជិះលើអ្វី? *(សត្វលា)*

៣. តើមនុស្សស្វាគមន៍ព្រះយេស៊ូវយ៉ាងណា? *(ដាក់អាវធំ និងធាងចាកក្រាលលើដី ហើយសរសើរដំកើងព្រះយេស៊ូវ)*

៤. តើអ្នកគួរសរសើរព្រះយេស៊ូវនៅពេលណា? *(គ្រប់ពេលវេលា)*

៥. តើបទសរសើរមួយណាដែលអ្នកពេញចិត្ត? *(ឱ្យកុមារឆ្លើយ)*

## ៧. ហត្ថកម្ម៖ «សរសើរតម្កើងព្រះយេស៊ូវ»

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាស់ហត្ថកម្ម កូល័រទៀន កន្ត្រៃ កាវ (ឬស្កុតបិត)



១. ឱ្យក្រដាសហត្ថកម្មដែលបានបោះពុម្ពហើយទៅកុមារម្នាក់១សន្លឹកហើយឱ្យពួកគេតុបតែងវា។

២. ឲ្យសិស្សកាត់ស្លឹក និងដើមចេញ ហើយបិតវាជាប់គ្នា។

៣. ឲ្យក្មេងៗឈរតម្រង់ជួរ ហើយស្រែកថា "ហូសាណា! មានពរហើយអ្នកណាដែលមកក្នុងព្រះនាមនៃព្រះយេហូវ៉ា!"

៤. អ្នកអាចច្រៀងចម្រៀងសរសើរដំកើងនៅពេលក្មេងៗកំពុងគ្រវីស្លឹកត្នោត។

## ៨. ល្បែងកំសាន្ត "ហ្វូងមនុស្សស្វាគមន៍ព្រះយេស៊ូវយាងមកយេរូសាឡិម"



១. ជ្រើសរើសកុមារ ១០នាក់ ឲ្យកុមារចាប់ដៃគូរពីរៗនាក់ តាមមាឌរបស់ពួកគេ

២. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារម្នាក់ត្រូវ វារ ដោយដាក់ដៃគូររបស់ពួកគេ គេនៅពីលើខ្នងសំដៅទៅចុងម្ខាងនៃថ្នាក់រៀន។

៣. នៅពេលដែលពួកគេទៅដល់ចុងម្ខាងនៃថ្នាក់រៀនពួកគេត្រូវប្តូរអ្នកវារម្តង ហើយត្រូវ វារ ត្រឡប់មកទីចាប់ផ្តើមវិញ

៤. កុមារដែលមិនបានលេងអាចឈរទះដៃ នឹងស្រែកហ៊ោ ដោយគ្រវីធាងចាករបស់ពួកគេ សម្រាប់អ្នកលេង ដូចដែលពួកមនុស្សបានស្រែកស្វាគមន៍សម្រាប់ព្រះយេស៊ូវដែរ។

៥. ក្រុមណាដែលអាចវាត្រឡប់មកដល់ទីបានមុនគេក្រុមនោះជាអ្នកឈ្នះ។

៦. អ្នកអាចជ្រើសរើសកុមារ ១០នាក់ទៀតដើម្បីលេងប្រសិនបើមានពេលគ្រប់គ្រាន់។

៧. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា
នៅពេលដែលព្រះបានយាងចូលក្នុងទីក្រុងយេរូសាឡិម ហើយពួកមនុស្សបានសរសើរតម្កើងទ្រង់
ដោយហៅទ្រង់ថា ជាព្រះអង្គសង្គ្រោះ។

## ៩. ខគម្ពីរចងចាំ

**ទំនុកដំកើង ១១៨:២៦** *"សូមឲ្យព្រះអង្គ ដែលយាងមកដោយនូវព្រះនាមព្រះយេ ហូវ៉ា បានប្រកបដោយព្រះពរ។"*

## ១០. ចំរៀង

(*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ជីវិត ការសុគត់ និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវបានធ្វើឲ្យយើងអាចមានជីវិតអស់កល្បជានិច្ច តាមរយៈទំនាក់ទំនងជាមួយទ្រង់។ ទ្រង់គឺជាហេតុផលសម្រាប់ក្តីសង្ឃឹម និងក្តីសុខរបស់យើង។ សរសើរដំកើងព្រះយេស៊ូវចំពោះអ្វីៗទាំងអស់ដែលទ្រង់មាន! ការសរសើរដំកើងព្រះយេស៊ូវគឺច្រើនជាងការអរព្រះគុណព្រះអង្គ។ វាធ្វើឲ្យយើងផ្តោតលើសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង។ ព្រះយេស៊ូវចង់ឲ្យយើងសរសើរដំកើងទ្រង់ដោយផ្ទាល់ខ្លួន និងជាសាធារណៈ ដើម្បីឲ្យអ្នកឯទៀតឃើញ សេចក្តីស្រឡាញ់របស់ព្រះអង្គដែរ។ តើអ្វីខ្លះដែលអ្នកអាចសរសើរដំកើងព្រះយេស៊ូវដោយផ្ទាល់ខ្លួន? សរសើរដំកើងទ្រង់ដោយសរសេរនូវកិច្ចការមួយចំនួនដែលទ្រង់បានធ្វើសម្រាប់អ្នក ហើយអរគុណទ្រង់ និងចែករំលែកវាទៅកាន់អ្នកដទៃ ដើម្បីអោយអ្នកនោះទទួលព្រះពរផងដែរ។

# សរសើរដំកើងព្រះយេស៊ូវ!

១.ឱក្រដាស់ហត្ថកម្មដែលបានបោះពុម្ពហើយទៅកុមារម្នាក់
១សន្លឹកហើយឱ្យពួកគេតុបតែងវា។
២. ឲ្យសិស្សកាត់ស្លឹក និងដើមចេញ ហើយបិតវា ជាប់គ្នា។
៣. ឲ្យក្មេងៗឈរតម្រង់ជួរ ហើយស្រែកថា “ហូសាណា!
ឲ្យព្រះអង្គ ដែលយាងមកដោយនូវ ព្រះនាមព្រះយេហូវ៉ា
បានប្រកបដោយព្រះពរ! ”
៤. អ្នកអាចច្រៀងចម្រៀងសរសើរដំកើងនៅពេលក្មេងៗ
កំពុងគ្រវីស្លឹកត្នោត។

